# រឿង សច្ចៈ

មនុស្សជាច្រើន បានស្រែកតវ៉ានឹងព្រហ្មលិខិតថា អយុត្តិធម៌ណាស់ៗៗៗ ៗៗៗ ៗៗៗ។ តើពាក្យតវ៉ាទាំងនេះមានចំនួនប៉ុន្មាន? តើមានអ្នកដឹង អ្នកស្តាប់ អ្នកឆ្លើយពីពួកគេដែររឺទេ? ពួកគេតវ៉ាដើម្បីអ្វី? តើបញ្ហាប៉ុន្មានភាគរយត្រូវបានគេដោះស្រាយ? ចម្លើយភាគច្រើននោះគឺបញ្ហារត្រូវបានដោះស្រាយនិងសម្រេចតាមយថាកម្ម ឬតាមច្បាប់ធម្មជាតិ ខ្លាំងត្រូវតែឈ្នះខ្សោយ ធំត្រូវឈ្នះតូច។ ហេតុដូចនេះហើយទើបមានការបួងសួងកើតឡើង ពីសំណាក់អ្នកខ្សោយ អ្នកចាញ់ អ្នកគ្មានលទ្ធភាព ដើម្បីបញ្ចោតចិត្ត ឬលួងលោមសេចក្តីសង្ឃឹមរបស់ខ្លួន។ តែប្រសិនបើការបន់ស្រន់ ការបួងសួងពិតជាស័ក្តិសិទ្ធិមែន ពិភពលោកនេះប្រាកដជាគ្មានអ្នកក្រឡើយ ហើយសោកនាដកម្មផ្សេងៗក៏គ្មានច្រើនសន្ធឹកសន្ធាប់ដូចសព្វថ្ងៃនេះដែរ។ នៅក្នុងជីវិតរស់មិនថាមនុស្ស សត្វ ឬរុក្ខជាតិ តែងតែខិតខំជម្នះរាល់ឧបសគ្គ ដើម្បីភាពលូតលាស់របស់ខ្លួនក្នុងនោះការលះបង់ដើម្បីជីវិតរស់ក៏ខុសៗគ្នាហើយចាំបាច់ត្រូវតែមានលក្ខខណ្ឌអំណោយផលពីបរិយាកាសជុំវិញផង។ វល្លិគ្មានភ្លៀងសន្សើមមិនទាន់បែកគុម្ពផងត្រូវក្រៀមស្វិតក្រញង់គួរឲ្យសោកស្តាយ មិនខុសអ្វីពីអ្នកមានទេពកោសល្យ ប្រាជ្ញា និងឧត្តមគតិ តែគ្មានលទ្ធភាព និងឱកាសទៅរកភាពលូតលាស់បានទោះជាខិតខំក្រាញនន់ ព្យាយាមដោយស្មារតីតស៊ូយ៉ាងណាប្រៀបដូចជាការប្រឹងប្រែងជីកប្រឡាយ តែនៅទីបំផុត រកប្រភពទឹកមិនឃើញដូច្នោះដែរ។ ជាមួយគ្នានោះ មនុស្សមួយក្តាប់តូច ទោះមានអំណាចប្រាក់ចាយមិនអស់យ៉ាងណាក្តី ក៏នៅមានសេចក្តីលោភ មិនចេះស្កប់ស្កល់ប្រើវិធីបន្លំ កេងបំបាត់ធ្វើខ្លួនជាតិរច្ឆានមកគំរាមកំហែង ដោយអំពើឃោរឃៅផ្សេងៗ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន និងបក្សពួក ឬគ្រាន់តែចង់បង្ហាញពីអំណាចលើអ្នកទន់ខ្សោយតែប៉ុណ្ណោះ។ ដូច្នេះហើយ ទើបអ្នកទាល់ច្រក ឬអ្នកដែលគេបំពាន ស្រែកបន់ស្រន់រកអាទិទេព ឲ្យជួយដោះស្រាយ។

តើព្រះឥន្ទ្រជាស្តេចនៃទេវតា ជាប់កិច្ចអ្វី បានជាបណ្តោយឲ្យផែនដីរងនូវពាក្យអយុត្តិធម៌ច្រើនយ៉ាងនេះ?

ទេវតាជាច្រើនពាន់អង្គ ធ្វើដំណើរឆ្ពោះទៅកាន់ឋានសួគ៌លាន់កក្រើករំពងអាកាស ដោយយានជំនិះ ឬរាជរថប្លែកៗ សុទ្ធតែប្រកបដោយសក្តានុពលគួរឲ្យស្ញប់ស្ញែងមើលទៅហាក់ដូចជាកំពុងបង្អួតយានជំនិះគ្នាទៅវិញទៅមកដើម្បីបង្ហាញឫទ្ធានុភាពរៀងៗខ្លួន។ ទេព្ធាភាគច្រើនហែហមដោយជាយា និងបុត្រធីតា គ្រងដោយគ្រឿងអម្ពរគ្រប់ពណ៌មានតម្លៃលើសលប់ តុបតែងកាយចែងចាំងពន្លឺសក្បុស ស្ទើរខ្វាក់ភ្នែកដោយរតន៍មុនីផ្សេងៗ មានតម្លៃមិនអាចគណនាបាន។ គ្រប់អង្គទេវៈបោះជំហានតាមវិថី មានអមដោយដួងផ្កាយរយលានដួងកំពុងតែលោតពន្លឺផ្លិបផ្លែតលម្អរាត្រីមានទាំងផ្កាគ្រប់ប្រភេទបញ្ចេញពណ៌ និងក្លិនគួរឲ្យឈ្លក់វង្វេង។ ផ្កាដ៏មានតម្លៃជាច្រើនពាន់ទងត្រូវគេក្រងជាភួងមាលាលម្អក្បាច់ជារូបបេះដូង បញ្ជាក់ថា ទីនេះកំពុងមានពិធីសិរីមង្គល។

ឋានសួគ៌កំពុងប្រារព្ធពិធីអភិសេកបុត្រីព្រះឥន្ទ្រ និងបុត្រាព្រះឥសូរ។ កូនកំលោះកូនក្រមុំ កំពុងយាងគារវកិច្ចចំពោះភ្ញៀវជាទេវៈមកពីគ្រប់ទិសទី ចំណែកព្រះឥន្ទ្រ និងមហេសីឈរអមដោយជន្លង គឺព្រះឥសូរ និងព្រះជាយាចាំទទួលសួយសារជាចំណងដៃពីទេវៈទាំងឡាយ។ ទេវៈមួយអង្គដុះក្បាលពោះកំពីង ដើរឱនៗមកជិតព្រះឥន្ទ្រ រួចទូលសួរ៖

-ព្រះគុណម្ចាស់លើសិរសា! ទ្រង់សព្វព្រះទ័យនឹងការតុបតែងទីកន្លែងនេះថ្វាយព្រះអង្គទេ ក្រាបទូល?

ព្រះឥន្ទ្រងាកមកញញឹមហើយពោល៖

-ស្អាតហើយធំទូលាយល្អណាស់ព្រះធរណី! អរគុណដែលជួយផ្តល់ទីកន្លែង...

ព្រះធរណីឮព្រះឥន្ទ្រសរសើរ ខិតចូលកាន់តែកៀកហើយពោលបន្ត៖

-ព្រះអង្គជាឥន្ទ្រាធិរាជ! អំណាចចេស្តាធំឥតគណនា លើសទេវៈទាំងពួងទោះព្រះអង្គចង់រៀបអភិសេកបុត្រលើអម្ពរវេហាស៍ លើគិរីជលសា ឬដែនធរណីក៏គ្មាននរណាហ៊ានជំទាស់និងទ្រង់ដែរ!ក្រាបទូល...

ព្រះឥន្ទ្រាសើចហើយងាកទៅយកកែវទឹកចំណ្ណាហុចឲ្យព្រះធរណីសោយ។

-ហ៊ឺស!ហ៊ឺស!(ព្រះឥន្ទ្រាសើចសម្លេងក្នុងបំពង់ក)លោកប្រសប់និយាយណាស់!នេះទឹកចំណ្ណាអញ្ជើញសោយ!

-ព្រះគុណម្ចាស់ទូលបង្គំចង់ទូល...អ

ព្រះគង្គាកាត់សម្តីព្រះធរណី

-ព្រះធរណីសម្លាញ់!មានបន្ទូលច្រើនម្ល៉េះមិនឃើញទេវៈឯទៀតកំពុងតម្រង់ជួរថ្វាយព្រះពរ និងសួយសារទេឬ?

ព្រះឥន្ទ្រលើកដៃឃាត់ព្រះគង្គារហើយនិយាយថា៖

-មិនថ្វីទេព្រះគង្គា! ចុះលោកមានអ្វីចង់ទូលដែរ?

ភ្លាមនោះ ព្រះគង្គាមានឱកាស ក៏ចូលមកបង្គំគាល់ព្រះឥន្ទ្រតែម្តងទៅ៖

ទូលបង្គំសូមធានាខាងភេសជ្ជៈមានទឹកផល្លា ទឹកច័ណ្ឌ ទឹកក្រុតជាដើមក្រាបទូល។

-យើងអរ ណ៎!

ស្រាប់តែឃើញព្រះអគ្គីយាងក្នុងដំណើរឆេងឆោង ដោយស្រវឹងទឹកច័ណ្ឌ មិនចាំការតម្រង់ជួរតាមលំដាប់លំដោយឡើយ ខំប្រជ្រៀតចូលមកក្បែរព្រះឥន្ទ្រ រួចទូលថា៖

-បពិតព្រះឥន្ទ្រដ៏មានឫទ្ធិ ទូលបង្គំសូមថ្វាយជូនម្ហូបអាហារ ដល់ពិធីដ៏មានសិរីមង្គលនេះ សូមព្រះអង្គ

និយាយមិនទាន់ចប់សេចក្តីផង ព្រះអគ្គីដែលលង់ក្នុងអំណាចទឹកច័ណ្ឌស្រាប់ហើយនោះ ក៏សន្លប់លែងដឹងខ្លួន។ ព្រះឥន្ទ្រលើកដៃជាសញ្ញា ឲ្យសេនាទាញព្រះអគ្គីទៅម្ខាងរកកន្លែងគួរសម។ ឃើញឱកាសល្អមកដល់ ព្រះរាហ៊ូរំកិលខ្លួនមកក្បែរព្រះឥន្ទ្រ រួចមានបន្ទូល៖

-ទូលបង្គំសូមចូលរួមអបអរព្រះអង្គផង! ដែលបានភ្ជាប់ខ្សែលោហិតនឹងព្រះសូរ្យ ទូលបង្គំសូមថ្វាយកន្សែងទិព្វ។ កន្សែងនេះ បើបុត្រីព្រះអង្គបក់ហើយ នឹងនាំបុត្រី និងបុត្រសុណិសា ទៅក្រេបចន្ទទឹកឃ្មុំបានគ្រប់ទិសា ក្រាបទូល។

-ចំណែកទូលបង្គំសូមថ្វាយរាជដំណាក់ដ៏វិចិត្រ មានខ្យល់ត្រជាក់គ្រប់វេលា និងមានទាំងស្រះស្រង់សុគន្ធវារីធំទូលាយថែមទៀតផង ក្រាបទូល៖

ព្រះសូរ្យឆ្លើយដោយត្រេកត្រអាលថា៖

-អស្ចារ្យ! អស្ចារ្យ! អរគុណហើយព្រះចន្ទ្រ។

ព្រះឥន្ទ្របន្ថែម៖

-អរគុណហើយ ដែលចេះគិតគូរដល់បុត្រយើង

ព្រះយមចូលបន្ត៖

-ទូលបង្គំសូមថ្វាយសត្វខ្ទីងជាយានជំនិះមួយក្បាលក្រាបទូល

ទេវៈមួយអង្គលុតក្រាបពីចម្ងាយ

-ទូលបង្គំមកពីឆ្ងាយ គ្មានអ្វីក្រៅពីវនគជមួយក្បាល មានកម្លាំងឥតគណនា គជសានេះស័ក្តិសមជាយានសម្រាប់ឋានៈបុត្រីព្រះអង្គណាស់ ក្រាបទូល

-អ៊ូ្ហ! គីវនទេព្តាទេអ្វី! អរគុណហើយ ដែលបាននាំព្រះរាជអំណោយមកថ្វាយ។

គិរីរក្សទេវៈហៀបនឹងចូលបន្ត ស្រាប់តែព្រះឥន្ទ្រពោលៈ

-នំ! ព្រះវិស្ណុយាងមកហើយ តស់យើងនាំគ្នាទទួលទ្រង់សិនទៅ!

ព្រះវាយោចូលមកសួរគិរីរក្សទេវៈ

-ពិនំ! គិរីរក្សទេវៈ ចុះលោកបានអីមកថ្វាយព្រះឥន្ទ្រដែរ?

-ទូលបង្គំមានខ្ទមលម្ហៃប្រាំបីទិសមកថ្វាយជាចំណងដៃ គ្រាន់បុត្រីព្រះឥន្ទ្រសម្រាកព្រះកាយពេលវិស្សមកាល។

-យីអើ! គិរីរក្សទេវៈ អ្នកជាទេវៈមានឋានៈតូចតាចជាងពួកយើង ហេតុអីក៏អ្នកមានបារមី អាចរករបស់ទិព្វពិសេសៗយ៉ាងឆាប់រហ័សបែបនេះបាន ប្រាប់យើងផងមើល៍?(ព្រះវាយោសួរ)

-នេះដោយសារការសណ្ដោសប្រណីពីព្រះទេវៈសំខាន់ៗ ដែលចេះទុកចន្លោះឱកាសឲ្យទូលបង្គំកន្លងមក។

ព្រះវាយោងក់ក្បាលដោយយល់សម្តី

-អ៊ីចឹង! តស់យើងទៅទទួលដំណើរព្រះវិស្ណុ

ចាហើយព្រះវាយោចេញទៅ។ តែគិរីរក្សទេវៈរាងស្ទាក់ស្ទើរ រអាក្នុងចិត្ត។

វនរក្សទេវៈមកកេះតឿន

-ម៉េចមិនដើរឲ្យលឿនទៅគិរីរក្ស!

-អ៊ូ្ហ! វនរក្ស យើងជាទេវៈតូចតាច មិនហ៊ានទៅឈរប្រជ្រៀតជាមួយនឹងព្រះទេវៈសំខាន់ដូចជាព្រះចន្ទ្រ ព្រះសូរ្យ ព្រះធរណី ព្រះគង្គា ព្រះអគ្គី ព្រះភិរុណ ព្រះវាយោឡើយ។

វនរក្សលាន់មាត់ៈ

-នំ! ព្រះវិស្ណុមកដល់ហើយ! មានទាំងមហេសី និងបុត្រាទៀត គាត់ប្រើសេះសមានឫទ្ធានុភាពខ្លាំងអស្ចារ្យមែន។

គិរីរក្សទេវៈដកកអើតមើលពីចម្ងាយ ដោយលាន់មាត់សរសើរព្រះវិស្ណុថា៖

-ដំណើរខែងរ៉ែងឡូយណាស់! សមជាទេវៈខាងចម្បាំងពិតៗតែម្តង!

ស្នូរកក្រើកលាន់រំពងជាថ្មី បន្ទាប់ពីដំណើរយាងមកដល់របស់ព្រះវិស្ណុ បង្ហាញថាមានទេវៈប្រកបដោយអំណាចបារមីមួយអង្គទៀតនឹងមកបន្ត។

ទេវៈខ្លះហាក់ស្គាល់សន្ធឹកនោះ ក៏ខ្លួនថយទៅម្ខាង ខ្លះជម្លៀសខ្លួនចេញទៅឆ្ងាយ។ ពេលនោះព្រះចន្ទ្រតាមសួរព្រះធរណី៖

-នែ៎ ព្រះធរណី! ហេតុអីមិនទៅចាំទទួលដំណើរយាងមកដល់របស់ព្រះព្រហ្មនឹងគេ អ៊ីចឹង?

-ចុះព្រះចន្ទ្រម្តេចមិនទៅទទួលទៅ? គេចមកទីនេះធ្វើអ្វីដែរ?

-ឲ្យទៅទទួលម៉េចកើត បើយើងមិនមែនជាកូនចៅរបស់ព្រះអង្គផង កន្លងមកនរណាក៏ដឹងដែរថាព្រះអង្គធ្លាប់ដណ្តើមអំណាចគ្នារហូតដល់មានការបង្ហូរឈាមទៀតផង។

ព្រះធរណីគ្រវីញងខ្លួនហាក់រអើម៖

-មែនហើយ! ខ្ញុំនៅធុំក្លិនឈាមប្រឡាក់កាយខ្ញុំមិនទាន់បាត់ផង សង្គ្រាមលើកនោះឆាប់ចប់មែន តែសេនាទាំងសងខាងស្លាប់មិនតិចទេ។ ឆ្ងល់ដែរ ព្រះឥន្ទ្រ ព្រះព្រហ្មគ្មានរបួសកាយ សូម្បីប៉ុនក្រចកអ៊ីចឹងនំ?

ព្រះចន្ទ្រអស់សំណើចហើយនិយាយ៖

ឯងល្ងង់ណាស់! ធម្មតាអ្នកធំបារមីខ្ពស់ របួសទាំងប៉ុន្មានមានអ្នករាសីទាបចាំរងចម្លងគ្រោះឲ្យគ្រប់ពេល។

ព្រះធរណីសម្លឹងមើលទៅព្រះព្រហ្មរួចពោល៖

មើលន៏! ព្រះឥន្ទ្រឱបថើបព្រះព្រហ្មជិតស្និទ្ធណាស់ ព្រះមហេសីទាំងពីរក៏អ៊ីចឹងដែរ ដូចជារាប់អានគ្នាមែនទែន ប្រហែលភ្លេចរឿងកាលច្បាំងគ្នាពីមុនចោលអស់ហើយមើលទៅ!

ព្រះចន្ទ្រតប៖

អើ្អយ! ច្រើនលើក ច្រើនសារហើយនៅតែអ៊ីចឹង រកទុកចិត្តមិនបានទេអ្នកធំ!

ព្រះធរណីនិយាយហាក់មានទំនុកចិត្តថា៖

តែលើកនេះ មើលទៅព្រះព្រហ្មដូចជាដាក់ព្រះកាយជាងមុន សព្វដងព្រះអង្គសព្វព្រះទ័យទៅណាតែបន្តិច ក៏ប្រើហង្សទេពជាយានដែរ បែរជាពេលនេះយកគជសារីរលោងស្រិលជាយានជំនិះទៅវិញ។ ការផ្លាស់ប្តូរបែបនេះ ប្រហែលជាខ្លាចព្រះឥន្ទ្រចេស្តាហើយមើលទៅ។

ថ្វីត្បិតត្រឹមតែគជសា តែមើលកម្លាំងវាចុះគ្មានគូប្រៀបទេ ហេតុតែបុណ្យបារមីខ្ពស់ អាចជប់យានជំនិះល្អៗមកប្រើបានតាមចិត្ត (ព្រះចន្ទ្រលាន់មាត់)។

ព្រះធរណីឃាត់៖

ស្ដើយ! កុំពិចារណាច្រើនពេក សោយទឹកចំណ្ណៃវិញប្រសើរជាង។

តស់លើកកែវឡើង!

ភ្លាមនោះស្នូរសន្ទឹកលាន់រំពងជាថ្មី រញ្ជួយផ្អើលអស់ទេវៈទាំងឡាយ។ ព្រះឥន្ទ្រងាកទៅខ្សឹបដន្លង៖

-ឆាប់ទៅយាងមហេសី និងអ្នកដន្លងចេញទទួលព្រះឥសូរភ្លាមទៅ! (ហើយងាកទៅយាងព្រះព្រហ្ម ព្រះវិស្ណុ)

-សូមយាងៗ ព្រះឥសូរមហារាជមកដល់ហើយ។

-យាងក្រាបទូល! (ព្រះព្រហ្មបង្ហាញឥរិយាបថអញ្ជើញ)។

ទេវៈមានតំណែងសំខាន់ៗ ទោះនិយមខាងព្រះឥន្ទ្រ ឬព្រះព្រហ្មក៏ដោយ សុទ្ធតែចេញមកគារវកិច្ចស្វាគមន៍ព្រះឥសូរទាំងអស់។ ព្រះវាយោសួរទៅព្រះភិរុណ៖

-អ្ហ៎! ព្រះភិរុណ មើលទៅទេវៈទាំងឡាយហាក់ចូលចិត្តព្រះឥសូរណាស់ន៎!

ព្រះភិរុណឆ្លើយ៖

-មកពីព្រះអង្គជាទេវៈចាស់ជាងគេ មិនសូវចេះដៀមដាម ប្រទូសរ៉ាយដូចអង្គទេវៈឯទៀតៗ។

ព្រះវាយោមានគំនិតបដិសេធនឹងទស្សនៈរបស់ព្រះភិរុណភ្លាម៖

-មិនមែនទេ!មកពីព្រះអង្គភ្នែកច្រើនតែចេះបិទម្ខាងបើកម្ខាងអ៊ីចឹងហើយបានជាទេវៈទាំងឡាយចូលចិត្តទ្រង់។

ព្រះភិរុណឱនទៅជិតព្រះវាយោហើយខ្សឹប៖

-មានម្តងម្កាលព្រះឥសូរមិនសព្វព្រះទ័យនឹងទង្វើព្រះទេវៈខ្លះក៏ងងក់ហោះទៅពូនភពផ្សេងមួយរយៈក៏មានដែរ។

ព្រះឥសូរមកជិតដល់ ព្រះវាយោទាញដាយអាវព្រះភិរុណជាសញ្ញាឲ្យឈប់និយាយ រួចឱនគោរពអង្គព្រះឥសូរ។ ព្រះឥន្ទ្រ ព្រះឥសូរ ព្រះព្រហ្ម ព្រះវិស្ណុកំពុងថ្វាយទឹកច័ណ្ឌដល់គ្នាទៅវិញទៅមកដោយសោមនស្ស។ ទេវៈទាំងឡាយរីករាយសេពសោយអាហារនិងទឹកច័ណ្ឌយ៉ាងជោគជាំ។ចំណែកឯទេវៈបុត្រ ទេពធីតានាំគ្នារាំលេងហ៊ោកញ្ជ្រៀវដោយរីករាយ។ ទេពីជាព្រះជាយានៃអង្គទេវៈទាំងឡាយនៅចោមរោមថ្វាយចំណងដៃដល់មហេសីព្រះឥន្ទ្រ មានទាំងមហេសីព្រះព្រហ្មនៅក្បែរនោះផង។

-ព្រះមហេសីឥន្ទ្រាធិរាជ!ខ្ញុំម្ចាស់និងស្វាមីសូមថ្វាយគ្រឿងអលង្ការមួយឈុតជាចំណងដៃថ្ងៃមង្គលនេះ។សូមទ្រង់ទតចុះ!ទឹកល្អណាស់។

មហេសីព្រះឥន្ទ្រទតហើយមានបន្ទូល៖

-អរគុណណាស់!ទេពីព្រះភិរុណ (ហើយឱនខ្សឹបតិចៗបន្តរ) មានដំណឹងល្អប្អូនប្រុសអ្នកបានតំណែងជាជំនួយការព្រះឥន្ទ្រហើយ ម៉េចពេញចិត្តទេ?

ទេពីព្រះភិរុណបង្គំអរគុណមហេសីព្រះឥន្ទ្រដោយរីករាយនឹងដំណឹងនេះ។

-អរព្រះគុណម្ចាស់!ដែលបានជួយខ្នះខ្នែងក្នុងរឿងនេះ។

ព្រះមហេសីព្រះឥន្ទ្រញញឹមរួចនិយាយ៖

-សុទ្ធតែគ្នាឯងទេ!បើមិនជួយតើទៅជួយអ្នកណា!(មហេសីព្រះឥន្ទ្រទះស្មាទេពីព្រះភិរុណតិចៗហើយនិយាយ) សូមអញ្ជើញទៅសោយអាហារចុះ!

មហេសីព្រះព្រហ្មផ្ទៀងត្រចៀកស្តាប់ រអ៊ូក្នុងចិត្តម្នាក់ឯង៖

-យី! ត្រឹមជំនួយការព្រះឥន្ទ្របានមួយឈុតយ៉ាងថ្លៃ។ កាលពីងយើងឲ្យជួយក្តួយចូលធ្វើជាទីប្រឹក្សាស្វាមីយើង យើងបានត្រឹមតែព្រះទំរង់មួយវង់ប៉ុណ្ណោះ ហេតុអីតំណែងខាងស្វាមីយើងតម្លៃថោកម៉្លេះន៎!

ក្បែរឆាកតន្ត្រី ទេវបុត្រ ទេពធីតារាំលេងយ៉ាងណែនណាន់តាន់តាប់។ នៅតុម្ខាងក្បែរនោះឃើញមានទេវបុត្រ ទេពធីតាស្វាវៗកំពុងជជែកគ្នា។ ទេវបុត្រព្រះអគ្គីនិយាយ៖

-នែ៎! ទេវបុត្រទេពធីតាចេញពីពិធីនេះទៅ តើចង់ប្រណាំងយានជំនិះទេយើងមានជំនិះថ្មីកម្លាំងខ្លាំងអស្ចារ្យណាស់ តើមានអ្នកណាចង់ល្បងទេ?

ទេវបុត្រព្រះវាយោនៅជុំវិញតុម្ខាងទៀតទៀតឈរ

-ចាញ់យើងច្រើនលើកហើយ តើមានអាពិសេស លើអាពិសេសនេះឬអត់?

-ម្តងនេះយើងប្រាកដជាឈ្នះ(ទេវបុត្រព្រះអគ្គីតប)។

ទេពធីតាព្រះភិរុណាឃាត់៖

-តិចលោជ្រុលជ្រួសដូចមុនទៅ!ពួកអ្នកមិនខ្លាចបិតាមាតាដាក់ទោសទេអី?

-ខ្លាចអី!ទេពធីតា បិតាពួកយើងមិនដាច់ព្រះទ័យដាក់ទោសយើងទេ បើដាក់ទោស កូនមានតែគាត់សុខចិត្តបាក់មុខខ្លួនឯង។

-ចុះមិនខ្លាចយានជំនិះរបួសឬងាប់ទេហ្អេះ?

-ភ័យអី!បិតាពួកយើងមានបារមីពូកែណាស់ងាប់ពេលណាអាថ្មីមកដល់ពេល នោះ។

ទេវបុត្រ ទេពធីតាងក់ក្បាល់ជាសញ្ញាយល់ព្រមទាំងអស់គ្នា រួចនាំគ្នាទៅរាំបន្តរ ទៀត ។

អង្គទេវៈទាំងអស់កំពុងសប្បាយយ៉ាងងប់ងល់ ស្រាប់តែឋានសួគ៌រញ្ជួយ ដោយ មហាព្យុះព្យោមាបោកបក់ ធ្វើឲ្យសម្ភារៈក្នុងពិធីខ្ចាត់ខ្ចាយ ប៉ើងទៅលើវេហាស៍។ឃើញ ហេតុការណ៍ដូច្នេះ ព្រះឥសូរ ព្រះព្រហ្ម ព្រះឥន្រ្ទ ព្រះវិស្ណុ នាំគ្នាឡើងលើអាសនៈសមាធិ រកមូលហេតុរៀងៗខ្លួន។បន្តិចមកព្រះឥសូរលាន់មាត់៖

-មានរឿងអីហ្នំ!ហេតុអីបានជាមើលមិនឃើញមូលហេតុអ៊ីចឹង?

ព្រះព្រហ្មបើកព្រះនេត្រធំដោយភ្ញាក់ផ្អើល

-អំណាចចេស្តាទូលបង្គំឯណោះវិញក៏អស់ប្រសិទ្ធភាពដែរ។

ព្រះឥន្រ្ទពោល៖

-ទូលបង្គំប្រើញាណលែងបានហើយងងិតមើលអ្វីមិនឃើញទេ...

ឯព្រះវិស្ណុរអ៊ូរតិចៗ

-ខ្យល់នេះមកពីណា?ហេតុអ្វីសាហាវយ៉ាងនេះ?(រួចស្រែក)

ព្រះទេវៈទាំងអស់!សូមរួមកម្លាំងគ្នាបំបែកមហាព្យុះភ្លាមទៅ!

ទោះព្រះវិស្ណុ ព្រះឥសូរ ព្រះព្រហ្ម ព្រះឥន្រ្ទ ព្យាយាមប្រើសិល្ប៍យ៉ាងណាក៏មិនអាច ទប់ស្កាត់មហាព្យុះសង្ឃរានេះបានដែរ។ ពេលប្រើសិល្ប៍កាន់តែខ្លាំងព្យុះកាន់តែបក់

បោកខ្លាំងឡើងៗ ធ្វើឲ្យក្រឡាប់ចាក់ឋានសួគ៌ជាច្រើនជុំ។ ទេវៈខ្លះប៉ើងទៅលើអាកាស ហើយថែមទាំងមានភ្លៀងកាំបិត ពូថៅ កណ្ដៀវ មកកាត់ច្រៀកសម្លៀកបំពាក់និងអវៈយវៈទេវៈទាំងនោះផង រហូតដល់ព្រះឥសូរ ព្រះព្រហ្ម ព្រះឥន្ទ្រ ព្រះវិស្ណុ ធ្លាក់ពីអាសនៈទល់ផ្អកគង់នៅមួយកន្លែង។ ចំណែកទេវៈឯទៀតៗកំពុងថ្ងូរដោយពើតផ្សា។ ព្យុះក៏ស្ងប់ ពន្លឺឆព្វណ្ណរង្សីភ្លឺរន្ទាលពេញផ្ទៃអាកាស វេហាស៍ភ្លឺជាងសែងសូរិយា តែបែជាមានចំហាយត្រជាក់ដូចទឹកអម្រិតផ្សព្វផ្សាយមក។ ទេវៈទាំងអស់សម្លឹងមើលស្ទើរមានហ៊ានដកដង្ហើម។ ផ្សែងសក្បុសមួយដុំប្រាកដឡើងចំកណ្ដាលឆព្វណ្ណរង្សីនោះឃើញដូច្នោះ ព្រះឥន្ទ្រសួរទៅអព្ភូតហេតុដោយឆ្ងល់ថា៖

-តើអ្នកមកពីឋានណាបានជាធ្វើឲ្យឋានសួគ៌យើងក្រឡាប់ចាក់បែបនេះ?

សម្លេងអរូបផុសចេញពីដុំផ្សែងតបមកវិញ៖

-ម្នាលទេវៈទាំងឡាយ! អ្វីដែលកើតឡើងទាំងនេះមិនមែនជាស្នាដៃយើងទេ ហេតុទាំងឡាយសុទ្ធតែជាចំណងបាបកម្មដែលទេវៈគ្រប់អង្គចង និងពូតផ្ដុំដោយអង្គឯង។

ទេវៈទាំងអស់លាន់មាត់៖

-បាបកម្ម?

សម្លេងទេវៈអរូបបន្ថែម៖

-មែន! ទេវៈគ្រប់អង្គវង្វេងវិលវល់ជាប់ដោយមន្ទិល លោភៈភ្លេចកាតព្វកិច្ចខ្លួនជាទេវៈ ជាទីពឹងពាក់អាស្រ័យនៃសព្វសត្វផងទាំងពួង។

ឃើញព្រះធរណី ព្រះសូរ្យ ព្រះចន្ទ្រ ព្រះគង្គា ព្រះវាយោ ព្រះភិរុណ ព្រះអគ្គីសុទ្ធតែអស់ស្លឹកត្រចៀកទាំងសងខាងអង្គុយឱនមុខជ្រប់។

-ព្រះសូរ្យ! (សម្លេងទេវៈអរូបហៅព្រះសូរ្យ)

ឮហៅចំឈ្មោះខ្លួន ព្រះសូរ្យភ្ញាក់ព្រើត សម្លេងអរូបបន្តរ៖

-អ្នកមាននាទីបំភ្លឺលោក ហើយជាដៃស្ដាំព្រះឥន្ទ្រាធិរាជតែបែរជាបណ្ដោយឲ្យផែនដីជួបភពងងឹតទាំងថ្ងៃ ទុកឱកាសឲ្យពពួកអាប ខ្មោច ព្រាយ បីសាចជញ្ជាក់ឈាមអ្នកស្លូតត្រង់គ្មានញញើត។ ព្រះចន្ទក៏អ៊ីចឹងដែរ!កំណាញ់រស្មីរនោចដូចខ្មើត ខ្មើតដូចរនោចឡេមឡឺម ធ្វើការមិនប្រាកដជាធ្វើការ ចូលចិត្តសប្បាយនៅតែឋានសួគ៌ មិនជាទីពឹងដល់សត្វលោកសោះ។

ព្រះច័ន្ទ្រញញូច្នោះភក្ត្រឡើងក្រហមដោយការអៀនខ្មាស។

សម្លេងអរូបនិយាយដល់ព្រះភិរុណាវិញម្តង៖

-ឯព្រះភិរុណាវិញរវល់តែសប្បាយ មិនព្រមទម្លាក់ខ្លួនទៅលើផែនដី ធ្វើឲ្យរុក្ខជាតិរួញស្វិត មនុស្សលោករងនូវគ្រោះទុរ្ភិក្ស។ នៅមានទេវៈជាច្រើនទៀតប្រហែលជាដឹងខ្លួនថា ខ្លួនឯងខុសអីហើយមែនទេ?

ទេវៈទាំងអស់ឱនមុខចុះ  ព្រះឥន្រ្ទមើលជុំវិញខ្លួនចុះឡើង ឃើញគ្រប់គ្នាសុទ្ធតែរបួស មានន័យថា គ្រប់អង្គប្រឡាក់ប្រឡូសមិនស្អាតស្អំ។ សូម្បីតែព្រះឥសូរមើលទៅអង្គុយសំងំក្បែរអាសន្នៈធ្វើជាសមាធិ តាមពិតព្រះឥសូរដឹងថា ថ្នេរខោរបូតអស់មិនហ៊ានកម្រើក ខ្លាចរលេះក្រណាត់លេចកេរ្តិ៍ខ្មាស ចំណែកព្រះព្រហ្មធ្វើជាសុភាពមិនហ៊ានហើបមាត់ មកពីដឹងថាថ្ពុះធ្មេញទាំងក្រាសខ្មាសគេមិនហ៊ាននិយាយ ថែមទាំងគួចនៅកណ្តាលវាលគ្មានក្រណាត់គ្របផង បានជាមិនងើបតវ៉ា។ រីឯព្រះវិស្ណុដៃទាំង៦របស់ទ្រង់ក្លាយជាដៃសិប្បនិម្មិតប្រើមិនកើត ជើងក៏ខ្វិនមិនដឹងគិតយ៉ាងម៉េច ទើបងក់តែក្បាលភ្ញក់ៗ ស្របតាមសម្លេងទេវៈអរូបគ្រប់ពេល ដើម្បីលាក់បាំងកុំឲ្យខ្មាស់ទេវៈទាំងឡាយផង។ ព្រះឥន្រ្ទដឹង ហើយយល់ច្បាស់ពីស្ថានភាព ព្រះទេវៈសំខាន់ៗទាំងបីតែបែរជាធ្វើឲ្យព្រះឥន្រ្ទមានមោទនភាពថា មានតែអង្គអញប៉ុណ្ណោះដែលមិនប្រឡាក់បាបស្មោគគ្រោកជាមួយគេ។ រួចងើបឡើងដើរយ៉ាងស្វាហាប់មើលស្ថានការណ៍។ស្រាប់តែព្រះឥន្រ្ទភ្ញាត់មាត់៖

-ស៊ី!ស៊ីគេហ្នឹង!តើអ្នកណា?

ព្រះឥន្រ្ទជំពប់ជើងនឹងកាយទេវៈមួយអង្គគ្មានអវៈយវៈសល់តែដងខ្លួនធាត់កំពឹងទេវៈនោះខំនិយាយខ្សាវៗ៖

-ទូលបង្គំគឺវិនរក្សទេវៈ។

ព្រះឥន្រ្ទស្រែកដោយភ្ញាក់៖

-វិនរក្សទេវៈ! វិនរក្សទេវៈ!ទេវៈអរូបអ្នកប្រាប់បានទេតើគេបានប្រព្រឹត្តបាបអ្វីខ្លះ?

សម្លេងទេវៈអរូបឆ្លើយតបដោយគ្មានអស់អែក៖

-ព្រៃរាប់សិបម៉ឺនហិចតាត្រូវបំផ្លាញ ធ្វើឲ្យផែនដីរងនូវគ្រោះធម្មជាតិសត្វព្រៃបាត់ជម្រក...។

ព្រះឥន្ទ្រសួរដោយភ្ញាក់ផ្អើល៖

-បាត់បង់ព្រៃរាប់សិបម៉ឺនហិចតា! ហេតុអ្វីច្រើនដល់ថ្នាក់នេះ?

វនរក្សទេវៈឆ្លើយ៖

-ក្រាបទូលព្រះអង្គ!ដោយសារតែទូលបង្គំចង់ធ្វើទេវតាពេកតែបារមីបុណ្យទូលបង្គំមិនទាន់ដល់ មិនអាចមកកាន់ឋានសួគ៌បាន ដូច្នោះហើយទើបទូលបង្គំយកឈើទាំងនោះធ្វើជណ្តើរឡើងមកកាន់ឋានសួគ៌។ ចំណាយពិតប្រាកដពីផែនដីមកកាន់ឋានសួគ៌ចំណាយប្រហែល១០ម៉ឺនហិចតាប៉ុណ្ណោះ តែដោយបង់ទៅលើសំណឹកឲ្យព្រះធរណីព្រះគង្គា ព្រះវាយោ ព្រះភិរុណ ព្រះសូរ្យ និងតារាជាច្រើនដំណាក់ទើបចំណាយកើនឡើងបែបនេះ

ទេវៈប៉ុន្មានអង្គដែលវនរក្សទេវៈរ៉ាយរ៉ាប់ប៉ះពាល់ដល់ខ្លួននាំគ្នាងាកមកគ្រហឹមផិល តែត្រូវជាប់រឹងថ្គាមនិយាយមិនចេញ រើខ្លួនមិនរួចដោយអំណាចអាថ៌កំបាំងអ្វីមួយ។ ព្រះឥន្ទ្របន្តរដំណើរទៅមុខ ជួបនឹងទេវៈមួយអង្គទៀតកាយបែកសាច់ជាចម្រៀកៗស្ទើរពុំជាប់ឆ្អឹងដេកថ្ងូរហ៊ឺស។ ព្រះឥន្ទ្រសួរទេវៈនោះភ្លាម៖

-ចុះនេះជាអ្នកណាដែរ?

-ទូលបង្គំគឺគិរីរក្សក្រាបទូល...

ព្រះឥន្ទជ្រួញចិញ្ចើមបែបឆ្ងល់ ស្រាប់តែសម្លេងអរូបបន្លឺឡើងទៀត៖

-បាបទេវៈនេះគឺរំលើងភ្នំរាបស្មើដី ធ្វើឲ្យខូចបរិស្ថានបំផ្លាញរតនភណ្ឌ...

ព្រះឥន្ទ្រសួរកាត់ដោយសំណួរបែបចង់ដឹងបន្ថែម៖

-លោកគាស់រំលើងភ្នំធ្វើអី?

គិរីរក្សឆ្លើយ៖

-ព្រោះតែទូលបង្គំខំស្វែងរករតនៈមានតម្លៃ យកមុនីរតនៈទាំងនោះមកដាំលម្អបល្ល័ង្កព្រះអង្គឲ្យអ្នកផងខ្លបខ្លាចចេស្តា ស្ហួយបារមីព្រះអង្គឲ្យកាន់តែមានអំណាចលើសអស់ទេវៈទាំងពួង។

ព្រះឥន្ទ្រឮហើយក្តុកក្តួលក្នុងចិត្ត ងាកមុខចេញ បែរជាប្រទះឃើញទេវៈមួយអង្គទៀតគួរឲ្យខ្ពើមរអើមក៏សួរទៅទេវៈនោះ៖

-យី!ហេតុអីក៏អ្នកមានរូបកាយអាក្រក់យ៉ាងនេះ?

ព្រះឥន្ទ្រលាន់មាត់ពេលឃើញពោះទេវៈនោះបែកចំហរឃើញគ្រឿងក្នុងទាំងអស់មានសួត ប្រមាត់ ថ្លើម ដែលមានពណ៌ខ្មៅជាំ ហើយថែមទាំងខ្វាក់ភ្នែកទៀត។ ព្រះឥន្ទ្រចង់មើលឲ្យក្បែក ថាតើអ្នកនោះជានរណា ក៏ឱនទៅសួរ៖

-អ្នកណាគេហ្នឹង?

-ទូលបង្គំព្រះយម ក្រាបទូល (ព្រះយមឆ្លើយតបដោយសម្លេងខ្សាវៗ)។

ពេលបានដឹងថា ជនពិការភ្នែកនោះជាព្រះយម ទ្រង់ភ្ញាក់ស្ទើរដាច់ផ្ងារ។

-ព្រះយម!!!

ឃើញបារមីរបស់ទេវៈអរូបខ្លាំងក្លាដូច្នេះ ទេវៈទាំងអស់សម្ងំស្ងៀមមិនហ៊ានហើបមាត់សោះ។ ព្រះឥន្ទ្រក្នុងដំណើរខែងរ៉ែង ដោយគិតថាខ្លួនគ្មានហេតុភេទអ្វីបញ្ជាក់ថាជាប់បាបនឹងគេ កំពុងមានមោទនភាព ស្រាប់តែលាន់មាត់ថា៖

-អ្ហាក! នោះសំឡុយក្បិនយើងទេតើ! ហេតុអ្វីក៏មហេសីយើងយកទៅរុំកាយទៅវិញ! ចុះយើង?

ព្រះឥន្ទ្រឱនមើលក្រោម ហើយលាន់មាត់៖

-ម្ចាស់ថ្លៃ!!! ខំដើរសួរសុខទុក្ខគេអស់មួយនគរ លោកអើយ!

-សំណាងណាស់ ដែលព្រះឥន្ទ្រមានសល់បារមីនៅឡើយ ព្រោះព្រះឥន្ទ្រឆ្លាតចេះស្លៀកលីអូ។ ព្រះឥន្ទ្រលុតជង្គង់គ្រឹបដើម្បីលាក់បាំងកេរ្តិ៍ខ្មាស ហើយក៏ស្រែកអង្វរទេវៈអរូប៖

-ព្រះអង្គដ៏មានឫទ្ធិ សូមព្រះអង្គប្រាប់មកថា តើគួរធ្វើយ៉ាងណា ដើម្បីឲ្យឋានសួគ៌ប្រកបដោយសេចក្តីសុខសាន្តរុងរឿង?

ទេវៈអរូបតប៖

-យើងដឹងថាគ្រប់អង្គប្រឡាក់ដោយបាបកម្ម តែឋានសួគ៌មិនអាចក្រឡាប់ចាក់ដូច្នេះបានទេ។ ម្នាលទេវៈទាំងឡាយ! អ្នកមានភារៈច្រើនកំពុងរង់ចាំ បើឋានសួគ៌រលត់ផែនដីក៏ត្រូវបាត់បង់ដែរ។ ដូច្នេះគួរទេវៈទាំងឡាយរកវិធីសាស្ត្រ ធ្វើឲ្យចម្រើនទៅ

អនាគតប្រសើរជាង។ ម្នាលទេវៈទាំងឡាយ! សូមរំលឹកព្រះទ័យជ្រះថ្លាតាមគន្លងព្រះធម៌ សមាទានសីលដោយបរិសុទ្ធទៅ...

ទេវៈគ្រប់រូបក៏ធ្វើសមាទានសីលតាមសម្ដីរបស់ទេវៈអរូប។ ភ្លាមនោះរូបកាយទេវៈទាំងឡាយ មានសភាពដូចប្រក្រតីឡើញវិញភ្លាមៗដែរ។ ទេវៈទាំងឡាយរីករាយណាស់ ស្រាប់តែសម្លេងអរូបបន្ថែម៖

-លោភៈ ទោសៈ មោហៈ ជាសំរាម សូមកុំធ្វើធុងផ្ទុករបស់ទាំងនោះឡើយ។ ថ្វីបើម្នាលទេវៈមានរូបកាយដូចគ្រាមុន តែមហិទ្ធិឫទ្ធិត្រូវបាត់បង់ លុះណាតែទេវៈទាំងឡាយខំសន្សំបុណ្យឲ្យបានច្រើន ទើបមានបារមីឡើងវិញ។ តែបើនៅប្រព្រឹត្តបាបកម្មទៀតប្រាដកជាគ្មានអ្នកណាជួយបានទេ។ ម្នាលអ្នកប្រព្រឹត្តនឹងធ្លាក់ទៅឋានបាតដាលសោយគំរង់អសោច ដូចពពួកប្រេតតិរិច្ឆានមិនខាន។

ព្រះឥន្រ្ទថ្លែងអំណរគុណដល់ទេវៈអរូប ដែលបានជួយដាស់តឿន៖

-អរគុណណាស់ព្រះអង្គ! ថ្ងៃក្រោយពួកទូលបង្គំមិនភ្លេចខ្លួន ភ្លេចកាតព្វកិច្ចទៀតទេ។ ទូលបង្គំនឹងរៀបចំប្រព័ន្ធគ្រប់គ្រងប្រកបដោយតម្លាភាព និងយុត្តិធម៌តាមដែលមហាជនចង់បាន។

ទេវៈអរូបសំណូមពរ៖

-ឋានសួគ៌ក្ដី! ឋានមនុស្សក្ដី! មិនគួរជ្រើសយកវិធីផ្ដាប់មួយ ហើយទុកឲ្យភាគច្រើនរងទុក្ខវេទនាឡើយ។ យើងសោមនស្សនឹងពាក្យសន្យារបស់ទ្រង់ តែសូមទ្រង់កុំបង្អង់ថាចាំថ្ងៃក្រោយធ្វើអី សូម្បីតែពាក្យថា ថ្ងៃស្អែកក៏ឋានកណ្ដាលមិនអាចរង់ចាំបានដែរ។ គ្រាន់តែមួយពព្រិចភ្នែក ខណៈដែលព្រះអង្គ និងទេវៈផ្សេងៗទៀត វង្វេងក្នុងពិធីនេះក៏ឋានមនុស្សរងទុក្ខរាប់សិបឆ្នាំទៅហើយ ចុះទម្រាំតែចាំពាក្យថាថ្ងៃក្រោយ តើមនុស្សលោកត្រូវវេទនាប៉ុន្មានតំណទៀត? ឋានមនុស្ស ត្រូវការបន្ទាន់ នូវការអភិវឌ្ឍនូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធ ត្រូវការយុត្តិធម៌រាល់គ្រប់វិនាទី។ ទុក្ខវេទនាទាំងឡាយ កំពុងដង្ហោយរក និងរង់ចាំការជួយសង្រ្គោះពីព្រះអង្គទាំងឡាយផងដែរ។

ព្រះឥន្រ្ទឱនមុខហាក់មានសម្ពាធអ្វីមួយមកគ្របសង្កត់ បន្តិចមកក៏ងើបមុខមកសួរ៖

-ឱ! ព្រះអាទិទេពដ៏មានឫទ្ធិ! ទ្រង់ឈ្វេងយល់គ្រប់យ៉ាងបានឥតខ្ចោះដូច្នោះ តើព្រះអង្គមានព្រះនាមអ្វីដែរ?

ទេវៈអរូបឆ្លើយបដិសេធ៖

-យើងមិនមែនជាអាទិទេពទេ!ពេលអ្នកកើតមកមានយើងរស់នៅក្នុងបេះដូងអ្នក តែគ្រប់គ្នាមិនព្រមសម្លឹង មិនព្រមទទួលស្គាល់ ថែមទាំងបំពានលើយើងថែមទៀត។ ប្រសិនអ្នកស្គាល់ការពិត! ស្រឡាញ់ការពិត! អ្នកនឹងស្គាល់យើងជាមិនខាន។

ទេវៈតូចធំទាំងអស់គិតមួយស្របក់លាន់មាត់៖

-សច្ចភាព...!...! ៕

និពន្ធដោយ: **ណោង កន្និដ្ឋា**